00630508

F7/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 12 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 001/18-07-2007-ECCC/SC

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រឹម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA MILART**
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ:

---

# សេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តី សុំដាក់សារណា របស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីមកកាន់អង្គជំនុំជម្រះតុលាការកំពូល

---

**ផ្នែកគាំពារការការពារក្តី៖**

Rupert Abbott

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១**

ទី ស្រីនណា
Karim KHAN

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ៖**

កាំង ហ្កេកអ៊ាវ ហៅ “ឌុច”

**សហមេធាវីការពារក្តីជនជាប់ចោទ**

ការ សាវុត្ថ

កង ឫទ្ធារី

Alain WERNER
Brianne McGONIGLE

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

Silke STUDZINSKY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Annie DELAHAIE
Philippe CANONNE
Elizabeth RABESANDRATANA
Fabienne TRUSSES-NAPROUS
Christine MARTINEAU

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”) បានទទួល “សំណើរបស់អង្គភាពគាំពារការការពារក្តី សុំដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីនៃរឿងក្តីនៅអង្គជំនុំជម្រះតុលាការកំពូល” (“សំណើសុំ”)[1]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានចេញសាលក្រមប្រឆាំងនឹង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច (“សាលក្រម”)[2]។ សហព្រះរាជអាជ្ញា, ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១, ២ និង៣ បានដាក់បណ្តឹងសាទុក្ខមកកាន់អង្គជំនុំជម្រះតុលាការកំពូលប្រឆាំងនឹងសាលក្រម[3]។

---

[1] ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០, F7។

[2] E188 (កែសម្រួល)។

[3] “បណ្តឹងសាទុក្ខភ្លាមៗរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ចំពោះការសម្រេចដកឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីសាលក្រម” ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០, F8; “បណ្តឹងសាទុក្ខរបស់ហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ប្រឆាំងនឹងសាលក្រមចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០” ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១០, F9; “បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ *ហៅ* ឌុច” ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០, F10; “សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម (ក្រុម២) និងទឡ្ហីករណ៍បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម” ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ E188/12; “បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសាលក្រមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២” ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០, F11; “បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ប្រឆាំងនឹងសាលក្រមលើសំណង” ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០, F13; និង“សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០” ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ F14 (“សារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ”); និងសារណាឆ្លើយតបរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីការពារឌុចជំទាស់នឹងសាលក្រមដែលបានចេញនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០, F14/2។

២. នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ លោក **Richard J. Rogers** អតីតប្រធានផ្នែកគាំពារការការពារក្តី បានដាក់សំណើសុំមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល។ សំណើសុំនេះ ត្រូវបានដាក់ទៅកាន់ផ្នែកគ្រប់គ្រងតុលាការនៃអ.វ.ត.ក ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០។

៣. នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ សហព្រះរាជអាជ្ញា បានដាក់"ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គភាពគាំពារការការពារក្តីសុំដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីមកកាន់អង្គជំនុំជម្រះតុលាការកំពូល"("ចម្លើយតប")[4] ស្របតាមមាត្រា៨(៣) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")[5] ។

## II. ផ្នែកសំអាងហេតុ

### ក. ច្បាប់ជាធរមាន

៤. វិធានផ្ទៃក្នុងចែងដូចខាងក្រោម៖

> នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី ប្រសិនបើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ .... អង្គជំនុំជម្រះ អាចស្នើសុំ ឬ ផ្តល់ឱកាសឱ្យអង្គការ ឬ បុគ្គលណាមួយដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទៅនឹងបញ្ហាណាមួយ .... អង្គជំនុំជម្រះដែលពាក់ព័ន្ធ ត្រូវកំណត់ពេលវេលាឱ្យដាក់សារណានេះ ប្រសិនបើត្រូវធ្វើ។
>
> សារណាដែលធ្វើឡើងក្រោមវិធាននេះ ត្រូវប្រគល់ទៅឱ្យក្រឡាបញ្ជីរបស់ .... អង្គជំនុំជម្រះដែលពាក់ព័ន្ធ។ ក្រឡាបញ្ជី ត្រូវប្រគល់ឯកសារថតចម្លងមួយច្បាប់ទៅឱ្យសហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីដទៃទៀតដើម្បីមានឱកាសឆ្លើយតប។

---

[4] ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០, F7/1។

[5] អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៥។

សេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីមកកាន់អង្គជំនុំជម្រះតុលាការកំពូល (*Amicus Curiae*) ។

...

អង្គភាពគាំពារការការពារក្ដីត្រូវ៖... ញ-ផ្ដល់ជំនួយផ្នែកច្បាប់ជាមូលដ្ឋាន និងជួយគាំពារលើការស្រាវជ្រាវផ្នែកច្បាប់ និងការស្រាវជ្រាវ និងផ្ដល់ឯកសារដល់មេធាវីដែលមកការពារចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ[6]។

## ខ. អង្គសេចក្ដី

៥. អង្គភាពគាំពារការការពារក្ដី បានផ្ដល់មូលហេតុដែលអង្គជំនុំជម្រះតុលាការកំពូល គប្បីផ្ដល់ឱកាសឲ្យដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្ដីដូចខាងក្រោម៖

> សេចក្ដីជូនដំណឹងអំពីបណ្ដឹង[សាទុក្ខ]របស់សហព្រះរាជអាជ្ញា មានទឡ្ហីករណ៍បណ្ដឹងសាទុក្ខចំនួនបីដែលលើកឡើងពីបញ្ហាបច្ចេកទេសដ៏ស្មុគស្មាញនៃច្បាប់អន្តរជាតិ។
>
> គេអាចយល់ច្បាស់តាមរយៈសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីថា សហមេធាវី មានបំណងកម្រិតការលើកឡើងរបស់ខ្លួនត្រឹមតែបញ្ហាយុត្តាធិការ និងផ្ដោតទៅលើបញ្ហាច្បាប់ជាតិ។ ដូច្នេះ បញ្ហាជាច្រើនដែលជាប់ទាក់ទិននឹងច្បាប់អន្តរជាតិ រួមទាំងបញ្ហាដែលបានលើកឡើងនៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ទំនងជាមិនត្រូវបានលើកឡើងឲ្យបានក្បោះក្បាយដោយមេធាវីការពារក្ដីឡើយ។
>
> បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងរឿងក្ដី ឌុច គឺជាបណ្ដឹងសាទុក្ខលើកទី១ដែលត្រូវកាត់សេចក្ដីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ដូច្នេះ បញ្ហាថ្មីៗ និងស្មុគស្មាញជាច្រើននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នឹងត្រូវលើកយកមកពិភាក្សា និងសម្រេចជាលើកដំបូងផងដែរ៖ មានន័យថាសាលក្រមស្ថាពរក្នុងរឿងក្ដី ឌុច នឹងក្លាយជាយុត្តិសាស្ត្រដែលមានឥទ្ធិពលទៅលើការជំនុំជម្រះក្ដីក្រោយៗទៀតនៅអ.វ.ត.ក។ ដូច្នេះ វាចាំបាច់ដែលថា អង្គជំនុំជម្រះតុលាការកំពូល ត្រូវតែទទួលបាននូវព័ត៌មានពេញលេញអំពីទិដ្ឋភាពមួយចំនួននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។
>
> ...

[6] វិធានផ្ទៃក្នុង,វិធាន៣៣(១)-(២) និង១១(២)(ញ) វិសោធនកម្មលើកទី៦

00630513



ដោយសារតែសហមេធាវីរបស់ ឌុច មានបំណងកម្រិតសារណារបស់ពួកគេត្រឹមបញ្ហាយុត្តាធិការ និងផ្តោតទៅលើច្បាប់ជាតិនោះ សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីដែលបានបង្ហាញពីទិដ្ឋភាពដទៃទៀតនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នឹងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខនេះបានគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ។

ក្នុងនាមជាអង្គភាពមួយរបស់អ.វ.ត.កដែលជួយធានាឱ្យមានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ អង្គភាពគាំពារការការពារក្តី គឺជាអង្គភាពដ៏ស័ក្តិសមក្នុងការដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីនៅក្នុងបណ្តឹងសាទុក្ខនេះ[7]។

៦. សហព្រះរាជអាជ្ញា បានសង្ខេបអំពីហេតុផលក្នុងការជំទាស់របស់ខ្លួនទៅនឹងសំណើដូចខាងក្រោម៖

តាមវិធានផ្ទៃក្នុង [អង្គភាពគាំពារការការពារក្តី] មិនត្រូវបានអនុញ្ញាតឱ្យ...ដាក់សារណានៅចំពោះមុខអង្គជំនុំជម្រះទេ មិនថាក្នុងនាមមេធាវីការពារក្តី ឬ ជាអ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីនោះទេ។ តួនាទីផ្ទាល់នេះ ត្រូវបានចៅក្រមរបស់អ.វ.ត.ក ច្រានចោលយ៉ាងជាក់ច្បាស់រួចហើយនៅពេលធ្វើសេចក្តីសម្រេចលើវិធានផ្ទៃក្នុងដែលគ្រប់គ្រងលើនីតិវិធីរបស់តុលាការ។ លើសពីនេះទៀត អង្គភាពគាំពារការការពារក្តីដែលជាអង្គភាពផ្ទៃក្នុងរបស់អ.វ.ត.ក ដោយមានការទទួលខុសត្រូវក្នុងការជួយគាំទ្រដល់មេធាវីការពារក្តី ត្រូវបានហាមឃាត់ក្នុងការផ្តល់យោបល់ផ្នែកច្បាប់ឯករាជ្យរបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី។ ទោះបីជាយ៉ាងណាក៏ដោយ តាមតួនាទីដែលមានចែងក្នុងវិធានផ្ទៃក្នុង អង្គភាពគាំពារការការពារក្តី អាចផ្តល់ជំនួយផ្នែកច្បាប់ដែលចាំបាច់ក្នុងបណ្តឹងសាទុក្ខនេះដល់មេធាវីការពារក្តី ដើម្បីថ្លែងសំអាង និងឆ្លើយតបទៅនឹងរាល់បញ្ហាដែលពាក់ព័ន្ធទាំងអស់។ សហព្រះរាជអាជ្ញា គាំទ្រដល់ការស្នើសុំណាមួយរបស់អង្គជំនុំជម្រះក្នុងការដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី នៅពេលដែលប្រយោជន៍ និងវិសាលភាពរបស់វា ត្រូវបានកំណត់យ៉ាងត្រឹមត្រូវ បន្ទាប់ពីការដាក់សារណាបណ្តឹងសាទុក្ខ និងចម្លើយតបទាំងឡាយរបស់ភាគីទាំងអស់។ សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីត្រូវចេញពីបុគ្គល ឬ អង្គការឯករាជ្យដែលមានជំនាញក្នុងការដោះស្រាយបញ្ហាដែលបានលើកឡើង[8]។

---

[7] សំណើ, កថាខណ្ឌ២-៣, ៧-៩ (ជើងទំព័រត្រូវបានលុប)។

[8] ចម្លើយតប កថាខណ្ឌ១។

៧. អង្គភាពគាំពារការការពារក្តី និងសហព្រះរាជអាជ្ញា ពឹងផ្អែកលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ក្នុងការគាំទ្រការលើកឡើងរបស់ខ្លួនទីមួយៗ[9]។ ក្នុងសេចក្តីសម្រេចនេះ សាលាឧទ្ធរណ៍បញ្ជាក់ថាៈ

> យោងតាមវិធានទាំងអស់របស់យើង វិធាន៧៤ មិនត្រូវបកស្រាយឱ្យមានលក្ខណៈចង្អៀត ឬ បច្ចេកទេសនោះទេ។ បញ្ហាស្តីពីការស្នើសុំការអនុញ្ញាត អាចត្រូវបានបញ្ជាក់ដោយផ្ទាល់ពីអង្គជំនុំជម្រះ ឬ ជាធម្មតា ត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងខ្លឹមសារនៃពាក្យសុំ។ អ្នកអាចធ្វើអន្តរាគមន៍បាននោះ ត្រូវបានគេកំណត់និមយន័យយ៉ាងទូលំទូលាយថាជា "រដ្ឋ អង្គការ ឬ បុគ្គលណាមួយ" និង ទោះបីជាមានចម្ងល់របស់អង្គជំនុំជម្រះសាលាដំបូងលើចំនុចនេះក្តី យើងគិតថា និយមន័យនេះមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ក្នុងការរួមបញ្ចូល ជាអាទិ៍ ការិយាល័យការពារក្តី។ ការិយាល័យនេះ មានករណីយកិច្ចផ្តល់ការគាំពារដល់ចុងចោទទាល់ក្រ និងក្នុងករណីសមស្រប អាចស្នើសុំធ្វើអន្តរាគមន៍ដើម្បីការពារអត្ថប្រយោជន៍ជនជាប់ចោទទាំងនោះដែលមិនមានមេធាវីតំណាង ប៉ុន្តែជាជនជាប់ចោទដែលមានការចាប់អារម្មណ៍ពិតប្រាកដលើលទ្ធផលនៃសំណើរបស់ចុងចោទដ៏ទៃទៀត។ ទោះបីជាត្រូវបានគេអនុញ្ញាតតាមសំណើក្តីក៏ដោយ វាអាស្រ័យលើការវាយតំលៃរបស់តុលាការលើតំលៃនៃការគាំពារដែលខ្លួននឹងទំនងជាផ្តល់ឱ្យ។ នៅពេលដែលតុលាការ ទទួលបានព័ត៌មានកាន់តែច្រើនស្តីអំពីការលើកឡើងដែលបានស្នើនោះ ការវាយតំលៃកាន់តែមានលក្ខណៈងាយស្រួលសម្រាប់យើង[10]។

៨. សហព្រះរាជអាជ្ញា មានការយល់ឃើញត្រឹមត្រូវក្នុងការញែកសេចក្តីសម្រេចរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដាច់ចេញពីខ្លឹមសារនៃសំណើនេះ ពីព្រោះជនជាប់ចោទ ត្រូវបានតំណាងដោយសហមេធាវីជាតិពីររូបរួចហើយ[11]។ អង្គជំនុំជម្រះតុលាការកំពូល យល់ស្របទៅនឹងការយល់ឃើញរបស់សហព្រះរាជអាជ្ញាថា

---

[9] សហព្រះរាជអាជ្ញា ទល់នឹង Kallon, សេចក្តីសម្រេចលើសំណើរបស់ Redress Trust, គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស និង

[10] សេចក្តីសម្រេច *Kallon* កថាខណ្ឌ១០។

[11] ចម្លើយតប កថាខណ្ឌ៦-៨។

“វាមិនមែនជាតួនាទីរបស់អង្គភាពគាំពារការការពារក្តីទេ ក្នុងការដើរតួជាអ្នកជំនួសឱ្យមេធាវីអន្តរជាតិតាមរយៈការដាក់សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីនោះ”[12]។

៩. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលបំណងរបស់អង្គភាពគាំពារការការពារក្តី ក្នុងសំណើនេះ គឺដើម្បីបំពេញបន្ថែម លើសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា វិធានផ្ទៃក្នុងចែងថា ដោយសារជនជាប់ចោទ ត្រូវបានតំណាងដោយសហមេធាវីជាតិពីររូប លទ្ធភាពសមស្របតែមួយគត់ដែលអង្គភាពគាំពារការការពារក្តី អាចបំពេញអណត្តិរបស់ខ្លួន គឺការជួយគាំពារផ្នែកច្បាប់ដល់ជនជាប់ចោទ និងសហមេធាវីការពារក្តីដែលអនុលោមតាមវិធាន១១(២)(ញ)នៃវិធានផ្ទៃក្នុង។ តាមរយៈសហមេធាវីរបស់ខ្លួន ជនជាប់ចោទ មានសិទ្ធិទទួល ឬ បដិសេធជំនួយផ្នែកច្បាប់និងការគាំទ្រនានារបស់អង្គភាពគាំពារការពារក្តី។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា សារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តី គួរតែជាការិយាល័យណាមួយ ឬ អ្នកដែល“មិនជាប់ពាក់ព័ន្ធនឹងតុលាការ”[13]។ យោងតាមហេតុផលខាងលើនេះ គប្បីអង្គជំនុំជម្រះតុលាការកំពូល សម្រេចបដិសេធសំណើសុំនេះជាអសារបង់។

---

[12] ចម្លើយតប កថាខណ្ឌ១១។

[13] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្កេកអ៊ាវ ហៅឌុច “ឌុច”, សំណុំរឿង ០០១/១៨/០៧/២០០៧- អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ ០២)អ.ប.ជ, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨, D99/3/42, កថាខណ្ឌ ២០ (ពណ៌នាសារណារបស់អ្នកដែលមិនមែនជាគូភាគីក្នុងរឿងក្តីជាក់លាក់មួយដែលអង្គបុរេបានស្នើសុំ “ដែលមិនពាក់ព័ន្ធនឹងតុលាការ ឬការិយាល័យណាមួយរបស់ខ្លួន”)។

## III. ផ្នែកសម្រេចសេចក្តី

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជា ឯកច្ឆ័ន្ទៈ**

- បដិសេធសំណើសុំ៕

**រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**